ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី　　　　**សាលនាមប្រជារាស្ត្រខ្មែរ**

លេខ : ៣៩៥　　　　　　　　**តុលាការកំពូល**

ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១

**សាលដីកា**　　　　　　បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ១២ ខែមករា

លេខ : ០១　　　　　　ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤

| | | |
|---|---|---|
| ១- ឯកឧត្តម | ឃឹម ប៉ុណ្ណ | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២- លោក | ជីវ កេង | ជាចៅក្រម |
| ៣- លោក | ប្រាក់ គីមសាន | ជាចៅក្រមរបាយការណ៍ |
| ៤- លោក | ឈឹម ស៊ីផល | ជាចៅក្រម |
| ៥- លោក | ស៊ិន ឌីម | ជាចៅក្រម |
| ៦- លោក | ប៉ែន សាវឿន | ជាចៅក្រម |
| ៧- លោក | សោម សិរីវឌ្ឍ | ជាចៅក្រម |
| ៨- លោក | គង់ ភីរុន | ជាចៅក្រម |
| ៩- លោក | យស់ សួខឿន | ជាចៅក្រម |

ក្រឡាបញ្ជី

កញ្ញា　　ហុក សុខធុល

តំណាងមហាអយ្យការ

លោក　　ឈួន ចាន់ថា　　ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៧០"ឈ"ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧១ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ :

-រវាងដើមចោទឈ្មោះ ឃឹម សុជាត (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរ នាយកក្រុមហ៊ុនសំណង់ ទីលំនៅ៧ផ្ទះលេខ១៤១ ផ្លូវលេខ១១៣ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

- មានមេធាវី លោក ឈុន វិនីតា

-និងចុងចម្លើយឈ្មោះយស់ រុំ (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥៣ឆ្នាំ មុខរបរធ្វើការជំនួសកូន យស់ សុគន្ធារី ទីលំនៅផ្ទះលេខ២២៣E₀ ផ្លូវ៣៦០ សង្កាត់បឹងកេងកង III ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

– មានមេធាវី លោក ឡាយ សំណាង

**<u>កម្មវត្ថុបណ្តឹង</u>** : ប្តឹងសុំបង្កើតក្រុមប្រឹក្សាញាតិ ដើម្បីថែរក្សាទ្រព្យសម្បត្តិអោយគង់វង់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ២៣៧ ចុះថ្ងៃទី១៣ ខែ០៧ ឆ្នាំ២០០១ របស់លោក យឹម សុជាត ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៧០ "ឈ" ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៥៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ របស់ឈ្មោះយឹម សុជាត ប្តឹងសុំបង្កើតក្រុមប្រឹក្សាញាតិដើម្បីថែរក្សាទ្រព្យសម្បត្តិរបស់អ្នកឧកញ៉ាយស់ សុគន្ធារី ឱ្យបានគង់វង់ ដោយហេតុថា កាលពីថ្ងៃទី១៥ ខែមករាឆ្នាំ១៩៩៩ អ្នកឧញ៉ាយស់ សុគន្ធារី ត្រូវបានជនមិនស្គាល់មុខលបលួចធ្វើឃាដមិនបានសំរេច បណ្តាលឱ្យរងគ្រោះយ៉ាងធ្ងន់ធ្ងរជាទីបំផុត ជនរងគ្រោះបានបាត់បង់សមត្ថភាពមិនអាចគ្រប់គ្រងទ្រព្យសម្បត្តិ មិនអាចថែរក្សាកូន៣នាក់ ដែលជាអនីតិជនហើយសព្វថ្ងៃកំពុងសំរាកព្យាបាលជំងឺនៅបរទេស ជៀសវាងការកេងប្រវ័ញ្ច ការបាត់បង់ទ្រព្យសម្បត្តិជាយថាហេតុ ទើបខ្លួនប្តឹងសុំដូចខាងលើ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២២៤"ង"ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ :

១-ទទួលពាក្យបណ្តឹងសុំ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ របស់ដើមចោទឈ្មោះ យឹម សុជាត ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ចាត់តាំងក្រុមប្រឹក្សាញាតិរបស់ឧកញ៉ាយស់ សុគន្ធារី និងប្រគល់អំណាចព្យាបាលលើអនិតិជនទាំងបីនាក់គឺឈ្មោះយស់ វិស្ណា ភេទប្រុស អាយុ១៦ឆ្នាំ ឈ្មោះយស់ ច័ន្ទសត្យា ភេទប្រុស អាយុ០៩ឆ្នាំ ឈ្មោះយឹម ស្រីពេជ្ររចនា ភេទស្រី បច្ចុប្បន្ន អាយុ០៦ឆ្នាំ ដែលជាកូនរបស់អ្នកឧកញ៉ា យស់ សុគន្ធារី ដែលមានសមាសភាពដូចតទៅ :

- លោកចៅសង្កាត់ដែលមានសមត្ថកិច្ចលើអចលនៈទ្រព្យ និងអចលនៈទ្រព្យជាកម្មសិទ្ធិរបស់អ្នកឧកញ៉ា យស់ សុគន្ធារី តាំងនៅជាអធិបតី ។

- លោកយឹម សុជាត អាយុ៤១ឆ្នាំ ទីលំនៅផ្ទះលេខ៤១ ផ្លូវ១១៣សង្កាត់បឹងព្រលិត ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ជាសមាជិក ។

- អ្នកស្រីឃឹម ប៊ិច អាយុ៥០ឆ្នាំ ទីលំនៅភូមិម៉ុងបារាំង សង្កាត់៣ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ជាសមាជិក ។

- លោកស្រី យស់ វុំ អាយុ៥៣ឆ្នាំ ទីលំនៅផ្ទះលេខ២៣ ផ្លូវ៣៦០ សង្កាត់បឹងកេងកងបី ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ជាសមាជិក ។

- លោកយស់ វណ្ណឌី អាយុ៣៩ឆ្នាំ ទីលំនៅផ្ទះលេខ៤០ ផ្លូវលេខ២៤២ សង្កាត់ចតុមុខ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ជាសមាជិក ។

- លោកយស់ តារា ទីលំនៅផ្ទះលេខ២៣ ផ្លូវ៣៦០ សង្កាត់បឹងកេងកងបី ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ជាសមាជិក ។ ចាប់ពីពេលនេះតទៅ យោងតាមសារាចរលេខ ១០២៨ រ.វ.ភ.ព-៩៩ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៩៩ របស់ក្រសួងយុត្តិធម៌ និងមាត្រា៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ០៦ ក្រ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ។

ក្រុមប្រឹក្សាញាតិមានសិទ្ធិដូចតទៅ ៖

- ធ្វើជាអាណាព្យាបាលលើអនីតិជនទាំងបីនាក់គឺ ៖ឈ្មោះយស់ វិស្ណុរ៉ា ភេទប្រុស បច្ចុប្បន្នអាយុ១៦ឆ្នាំ ឈ្មោះយស់ ច័ន្ទសត្យា ភេទប្រុស បច្ចុប្បន្នអាយុ៩ឆ្នាំ ឈ្មោះឃឹម ស្រីពេជ្ររចនា ភេទស្រី បច្ចុប្បន្នអាយុ៦ឆ្នាំ ដែលជាកូនរបស់អ្នកឧកញ៉ាយស់ សុគន្ធារី និងត្រូវចាត់ទុកបាលិតទាំងបីដូចជាកូនបង្កើតនៃខ្លួន ។

- ថែរក្សាគ្រប់គ្រង ទុកអោយបានគង់វង្សទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់អសមត្ថជន និងបាលិតទាំងបី ដែលស្ថិតនៅក្រោមអំណាចព្យាបាលរបស់ខ្លួន ដែលបានហាមឃាត់ក្នុងដីកាលេខ ០៨ប្រ "ង" ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៩៩ និង ដែលមិនបានហាមឃាត់ក្តីចាប់ពីពេលទទួលសិទ្ធិនេះតទៅ ។ មានសិទ្ធិចាត់ចែងគឺលក់ បញ្ចាំ នូវទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់អសមត្ថជន និងបាលិតទាំងបីក្នុងករណីដើម្បីយកប្រាក់ផ្គត់ផ្គង់ដល់ការសិក្សាអប់រំបីបាច់ ទូទាត់បំណុលដែលមានពីមុនមកព្យាបាលជំងឺរបស់អសមត្ថជនឈ្មោះយស់ សុគន្ធារី និងបាលិតទាំងបីខាងលើ ហើយសិទ្ធិចាត់ចែងក្រៅពីលក្ខណៈទាំងនេះត្រូវហាមឃាត់ ។

-ចេញមុខតំណាងឱ្យអសមត្ថជនឈ្មោះយស់ សុគន្ធារី និងបាលិតទាំងបីខាងលើក្នុងកិច្ចការទាំងអស់លើផ្នែកស៊ីវិលពាណិជ្ជកម្ម និង ឧស្សាហកម្ម និងបន្តសកម្មភាពដែលមានពីមុនមក។

-ជាតំណាងឱ្យអសមត្ថជនឈ្មោះយស់ សុគន្ធារី និង បាលិតទាំងបីខាងលើ ក្នុងនាមជាម្ចាស់បំណុល និងកូនបំណុល ក្នុងការទាមទារតវ៉ា និងទូទាត់បំណុល ដែលមានពីមុនមកនៅចំពោះមុខតុលាការ និងអាជ្ញាធរមានសមត្ថកិច្ច ។

-ត្រូវចាត់ចែងនូវផលទុនរបស់អសមត្ថជន និងបាលិត ដើម្បីប្រយោជន៍របស់អសមត្ថជន និងបាលិតនោះ ។ ត្រូវរាយការណ៍ពីចំណាយ និងផលទុនដែលខ្លួនបានទទួល ។

**<u>ភាតព្វកិច្ច</u> :**

-ទទួលខុសត្រូវលើព្យសនកម្ម ដែលបណ្តាលមកពីខ្លួនមានការធ្វេសប្រហែស និងចេតនាទុច្ចរិត ក្នុងពេលវេលាបំពេញសិទ្ធិ ជាអ្នកគ្រប់គ្រងទ្រព្យ ។ សិទ្ធិ និងភាតព្វកិច្ចដែលបានកំណត់ខាងលើត្រូវរំលាយពេលដែលអ្នកអសមត្ថជនឈ្មោះយស់ សុគន្ធារី មានសមត្ថភាពពេញលេញឡើងវិញ និងបាលិតទាំងបីបានដល់កាលនីតិភាព ឬដល់នូវអត្តាធិនភាពតទៅ ។

៣-បង្គាប់ឱ្យដើមបណ្តឹងសុំឈ្មោះយឹម សុជាត បង់ប្រាក់ប្រដាប់ក្តីតាមការស្ម័គ្រចិត្ត គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វីង១.៨០០រៀល ប្រាក់ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល សរុប៧.០០០រៀល ប្រាក់នេះកាត់យកពីប្រាក់៧.០០០រៀល ដែលដើមបណ្តឹងសុំ បានបង់រួចជាស្រេចនៅតុលាការក្រុងភ្នំពេញ ។

៤-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខអ្នកប្តឹងសុំ និងសមាជិកបីនាក់នៃក្រុមញាតិរបស់អ្នកឧកញ៉ា យស់ សុគន្ធារី សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល២ខែ គិតចាប់ពីពេលនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់អ្នកស្រីយស់ រុំ មិនសុខចិត្ត និងសាលក្រមរដ្ឋប្បវេណីលេខ២៤"ង"ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ០២"ខ" ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់ឈ្មោះយស់ រុំ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ២៤"ង" ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការទាំងមូល ។

៣-រឹបអូសយកប្រាក់ប្រដាប់ក្តីចំនួន១៣.០០០រៀល ដែលឈ្មោះយស់ រុំ បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០រៀល និងអាជ្ញាធរតុលាការ៥.០០០រៀល សរុប១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តីនិងមេធាវីរបស់ចុងចំលើយ សំរេចបើកផ្លូវប្តឹងសាទុក្ខកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣០ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០របស់ឈ្មោះ យស់ រុំ ប្តឹងមិនសុខចិត្តពីសាលដីកាសាលាឧទ្ធរណ៍លេខ២៤"ង" ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ មិនសុខចិត្តលើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៣១ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០០ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៣០ ចុះថ្ងៃទី១៩ ខែមេសា ឆាំ២០០០ របស់មេធាវី គង់ ហេង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ០២"ខ" ចុះថ្ងៃទី៤ ខែមករាឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១២៥ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រីយស់ រុំ បានបង់ទុកនៅតុលាការកំពូលចំនួន ១៩.០០០រៀល គឺ :

ពន្ធចុះបញ្ជីក្តី និងពន្ធប្តឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

ចំណាយក្នុងការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀលហើយតំរូវឱ្យលោកឃឹម សុជាត សងប្រាក់១៩.០០០រៀល នេះទៅអ្នកស្រីយស់ រុំ វិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៦ ខែកក្កដាឆ្នាំ២០០០

បានឃើញដីកាបញ្ជូនលេខ៣២៨/២០០០សណ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ របស់តុលាការកំពូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៤"ឈ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ៧១ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ឡើងវិញ តាមអំណាចសាលដីកាលេខ១៣១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០០ របស់តុលាការកំពូល ។

២-សំរេចថា អ្នកឧកញ៉ាយស់ សុគន្ធារី នៅតែមានសិទ្ធិអំណាចគ្រប់គ្រងចាត់ចែងក្នុងនាមជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួនដោយផ្ទាល់ និងនៅតែមានអំណាចជាមេបា ជាអាណាព្យាបាលលើកូនរបស់ខ្លួនទាំងពីរ ដដែល ។ តាមបញ្ញត្តិមាត្រា៤៤ នៃច្បាប់រដ្ឋធម្មនុញ្ញមាត្រា ៣ ,២០នៃច្បាប់ភូមិបាលមាត្រា១១៩ .១២០ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈកំបាំងមុខគូក្តីចំពោះមុខមេធាវី ចំណាយក្តី ឱ្យចុងចំលើយឈ្មោះទូត លុច កំបាំងមុខមេធាវីដើមចោទឈ្មោះអ៊ុក វ៉ាន់ដេត បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ១៩ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០១ របស់ឈ្មោះយឹម សុផាត ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ២៤ "ឈ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧០"ឈ" ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២២ ខែមីនាឆ្នាំ២០០១របស់ឈ្មោះយឹម សុផាត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស និង គតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ២៤"ឈ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខយឹម សុផាត ជាដើមចោទ និង តំណាងចុងចំលើយលោកមេធាវីទូត លុច ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញសាលដីការបៀបលេខ២២២ ចុះថ្ងៃទី០៩ ខែកញ្ញាឆ្នាំ២០០២របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបអោយធ្វើកោសល្យវិច្ឆ័យអំពីស្ថានភាព សុខភាពបច្ចុប្បន្នរបស់អ្នកឧកញ៉ា យស់ សុគន្ធារី ។ ក្នុងករណីចាំបាច់គប្បីចាត់ចៅក្រមតុលាការកំពូល អោយចុះទៅជួបផ្ទាល់អ្នកឧកញ៉ា ។

២-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០២ ។

បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា : បណ្តឹងសាទុក្ខរបស់ដើមចោទស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ចុះ ។

បានស្តាប់ចម្លើយរបស់លោក យឹម សុផាត (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលសវនាការថា : បានជាខ្លួនប្តឹងសាទុក្ខ ព្រោះខ្លួនយល់ឃើញថា ម្តាយរបស់ក្មេងដែលជាកូនរបស់ខ្លួន ឋិតនៅក្នុងភាពអសមត្ថភាព ខ្លួនសុំអោយតុលាការទៅពិនិត្យដល់កន្លែងជាក់ស្តែង ជៀសវាងការធ្វើរបាយការណ៍វិលោភ គឺសុំអោយតុលាការទៅពិនិត្យ និងសំរេចនៅកន្លែងនោះតែម្តង បើអ្នកជំងឺមានសភាពដូចក្នុង

របាយការណ៍របស់លោកចៅក្រមនោះ គាត់ប្រាកដជាមកចូលសវនាការទីនេះបាន ជាក់ស្តែងគាត់រស់នៅក្នុងមន្ទីរពេទ្យ៥ឆ្នាំ ទ្រព្យសម្បត្តិឋិតនៅក្នុងការគ្រប់គ្រងរបស់ម្តាយគាត់ ឃើញថាមានការបាត់បង់ទ្រព្យសម្បត្តិរបស់កូនខ្លួនដែលជាអនីតិជន ខ្លួនសុំអោយតុលាការធ្វើការពិចារណាលើរឿងនេះ បើតុលាការសំរេចមិនបង្កើតក្រុមប្រឹក្សាញាតិ ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ ខ្លួនសុំអោយតុលាការទទួលខុសត្រូវចំពោះកូនខ្លួនទៅអនាគត ។

បានស្តាប់ចម្លើយរបស់អ្នកស្រី យស់ រុំ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលសវនាការថា : កូនខ្លួនមិនអនុញ្ញាតិអោយបង្កើតក្រុមប្រឹក្សាញាតិនោះទេ ព្រោះនាងនៅមានស្មារតីចងចាំត្រឹមត្រូវគ្រាន់តែមិនអាចដើរបានប៉ុណ្ណោះ ហើយចំពោះខ្លួនជាម្តាយ គឺត្រូវតែជួយកូនធ្វើអ្វីៗ ដើម្បីកូនខ្លួនមិនកេងប្រវ័ញ្ចពីកូននោះទេ ។ ខ្លួនសូមបង្ហាញភស្តុតាង ដែលខ្លួនបានថតកូនក្នុងពេលថ្មីៗ តាមរយៈ VCD ដែលបានថតសំលេង និងរូបភាពអ្នកឧកញ៉ា យស់ សុគន្ធារី ជូនតុលាការពិនិត្យ និង សំរេចថា កូនខ្លួនមិនអនុញ្ញត្តិអោយបង្កើតក្រុមប្រឹក្សាញាតិនេះទេ ។

បានស្តាប់ចម្លើយបន្ថែមរបស់អ្នកស្រីយស់ រុំ ក្រោយពីតុលាការបានពិនិត្យមើលការចាក់ផ្សាយ VCD ថា :ខ្លួនសុំអោយតុលាការសំរេចលុបចោល ការបង្កើតក្រុមប្រឹក្សាញាតិនេះ ដើម្បីងាយស្រួលខ្លួនលក់ទ្រព្យសម្បត្តិ ដើម្បីយកលុយទៅព្យាបាលកូននៅប្រទេសអាមេរិក ព្រោះពេទ្យអាមេរិកបានធានាថា ព្យាបាលកូនតែប្រាំមួយខែកូនខ្លួនអាចដើរបាន អាស្រ័យហេតុនេះអាយុជីវិតកូនខ្លួនគឺអាស្រ័យទៅលើការសំរេចរបស់តុលាការនេះហើយ សូមតុលាការបញ្ចប់រឿងនេះតែត្រឹមនេះចុះ ដើម្បីខ្លួនលក់ទ្រព្យសម្បត្តិយកលុយទៅព្យាបាលកូនខ្លួន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឈុន វីនីតា ជាមេធាវីការពារអោយឃីម សុផាត នៅពេលសវនាការថា : ខ្លួនការពារអោយដើមបណ្តឹងសាទុក្ខ កូនក្តីខ្លួនប្តឹងនេះ គឺមិនចង់បានអ្វីទេ គោលបំនងគឺការពារជនប្រយោជន៍អោយកូនគាត់ដែលជាអនីតិជន ។ ដូច្នេះកូនក្តីខ្លួនអាចប្តឹងបានទាក់ទងទៅ និងទាយាទ១ និងទី២ គឺអសមត្ថជន ឆ្លងតាមការពិនិត្យមើល VCD រូបភាពអំបាញ់មិញនេះ ឃើញថា អ្នកមីងបាននិយាយមកនេះមានការចេញទឹកភ្នែក ដូចជាមានការបង្ខំអោយនិយាយ រឺក៏មានការសរសេរអោយគាត់អានតាម នេះមិនអាចយកជាការពិតបានទេ ព្រោះគាត់មិនបានលើកឡើងពីការបង្កើតក្រុមប្រឹក្សាញាតិនេះទេ ខ្លួនសូមអោយតុលាការពិចារណាលើរឿងនេះ ។ មួយទៀតបើពិនិត្យពីអសមត្ថជន ឃើញថាគាត់គ្មានសមត្ថភាពនោះទេ បានជាគាត់ផ្ទេរសិទ្ធិអោយអ្នកស្រីយស់ រុំ ជាអាណាព្យាបាល ហើយក្នុងនាមអាណាព្យាបាល នៅពេលចំណាយត្រូវតែមានបញ្ជីចំណាយច្បាស់លាស់ ។ ទាក់ទង់នឹងការប្តឹងនេះមិនមែនជាប្រយោជន៍អោយកូនក្តីខ្លួនទេ គឺដើម្បីកូនគាត់ដែលជាអនីតិជន សំណូមពរ ខ្លួនសូមអោយតុលាការពិចារណាហើយពិចារណាទៀតក្នុងករណីនេះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឡាយ សំណាង ជាមេធាវីការពារអោយអ្នកស្រីយស់ រុំ នៅពេលសវនាការថា : ក្នុងរឿងក្តីនេះលោកឃឹម សុជាត បានប្តឹងដោយអះអាងថា អ្នកស្រីយស់-សុគន្ធារី អសមត្ថជន ហើយមូលហេតុនៃការប្តឹងនេះមកពីការលក់អចលនៈវត្ថុរបស់ខ្លួនដើម្បីយកលុយទៅព្យាបាលតាមការផ្ទេរសិទ្ធិអោយអ្នកស្រីយស់ រុំ ហើយប្រាំឆ្នាំមកនេះ គឺអ្នកស្រីយស់ រុំ ជាអ្នកគ្រប់គ្រងថែរក្សា។ ហើយការប្តឹងឃាត់ទ្រព្យសម្បត្តិនេះ គឺដើម្បីផលប្រយោជន៍កូនទាំងពីររបស់គាត់ តែប៉ះពាល់ដល់ផលប្រយោជន៍អ្នកស្រីយស់ រុំ ដែលត្រូវការព្យាបាលកូនជាបន្ត ការព្យាបាលតទៅទៀតបាន ។ ចំណុចមួយទៀត គឺពលរដ្ឋទាំងអស់មានសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ខ្លួន តែអ្នកស្រីពុំមានសិទ្ធិទេ តាមពិកលោកឃឹម សុជាត បានលែងលះគ្នារួចហើយ តាមច្បាប់អាពាហ៍ពិពាហ៍បុគ្គលដែលបានលែងនេះហើយគ្មានសិទ្ធិមកលើទ្រព្យសម្បត្តិគេទេ គាត់គឺជាអ្នកដ៏ទៃសុទ្ធសាធ ។ម្យ៉ាងទៀតការលើកឡើងរបស់លោកមេធាវីថា ការនិយាយរបស់គាត់មានចេញទឹកភ្នែក នេះជារឿងធម្មតាទេ ក្នុងការឈឺចិត្តដែលទ្រព្យសម្បត្តិរបស់ខ្លួនមិនអាចលក់បាននោះ ហើយលោកមេធាវីថាការបង្កើតក្រុមប្រឹក្សាញាតិ គឺជាការត្រឹមត្រូវនោះ ខ្លួនសុំបដិសេធ។ យោងតែខ្សែអាត់ និងលិខិតបញ្ជាក់ពីមន្ទីរពេទ្យ ខ្លួនសូមអោយតុលាការមេត្តាតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោកឈុន វីនីតា នៅពេលសវនាការថា : រឿងក្មេងមិនចង់ទៅខាងម្តាយនោះ វាជាសិទ្ធិរបស់ក្មេង ដែលវាចង់មកខាងឪពុកហើយក្មេងត្រូវការរៀនសូត្រលោក ឃឹម សុជាត គាត់មានសមត្ថភាពផ្តល់អោយកូនគាត់រៀនសូត្រ ។ ហើយកូនក្តីខ្លួនសុំបង្កើតក្រុមប្រឹក្សាញាតិនេះ គឺមិនប៉ះពាល់ដល់ទ្រព្យសម្បត្តិនោះទេ គឺគ្រាន់តែសុំអោយមានការត្រួតពិនិត្យត្រឹមត្រូវក្នុងការចំណាយ ហើយបើការចំណាយនោះមិនគ្រប់គាត់ចេញបន្ថែមទៀត ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោក ឡាយ សំណាង នៅពេលសវនាការថា : ការសុំបង្កើតក្រុមប្រឹក្សាញាតិដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិនោះ គឺពុំត្រឹមត្រូវទេ ក្នុងនាមអ្នកឧញ៉ា យស់-សុគន្ធារី ជាម្តាយគាត់មានសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់គាត់ គាត់ចង់អោយអ្នកណា ចែកឱ្យកូនណា រឺក៏មិនអោយកូនណាក៏បានដែរ ព្រោះវាជាសិទ្ធិរបស់គាត់ គ្មានខុសច្បាប់នោះទេ ក្នុងករណីដែលគាត់នៅរស់ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីនៃគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ២៣៧ ចុះថ្ងៃទី១៣ ខែកក្កដាឆ្នាំ២០០១របស់លោកឃឹម សុជាត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះដល់អង្គសេចក្តីបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអានុភាពផងដែរ ក្នុងរឿងរដ្ឋប្បវេណី ។

-យល់ឃើញថា ការដែលលោកឃឹម សុជាត និងមេធាវីរបស់លោក លើកឡើងនៅក្នុងសារណា និងនៅពេលសវនាការនេះថា អ្នកស្រីយស់ សុគន្ធារី បាត់បង់សមត្ថភាពហើយ លោកសុំឱ្យបង្កើតក្រុមប្រឹក្សាញាតិ ដើម្បីគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិរបស់អ្នកស្រីយស់ សុគន្ធារី ពីព្រោះថា ទ្រព្យសម្បត្តិសព្វថ្ងៃពុំមានអ្នកណាថែរក្សា អាចធ្វើឱ្យបាត់បង់ ហើយខាតបង់ដល់ផលប្រយោជន៍របស់កូនដែលបានមករស់នៅជាមួយលោកនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា :

ក-/ តាមព្រឹត្តប័ត្រពេទ្យទូទៅ របស់មន្ទីរពេទ្យ ឆ រ៉យ ប្រទេសវៀតណាម និងតាមលិខិតបញ្ជាក់ជម្ងឺ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៣ របស់មន្ទីរពេទ្យTRIEYAN បញ្ជាក់ច្បាស់ណាស់ថា អ្នកជម្ងឺមានស្មារតីចងចាំទំនាក់ទំនងបានស្រួល មិនវិកលចរិក ខួរក្បាលនៅល្អ អាចឆ្លើយឆ្លងបានស្រួល ។ ដូចនេះអ្នកស្រីយស់ សុគន្ធារី ពុំមានការបាត់បង់សមត្ថភាពខាងស្មារតីទេ គ្រាន់តែបាត់បង់សមត្ថភាពផ្លូវកាយតែប៉ុណ្ណោះ ហើយអ្នកស្រីមិនឯកភាពឱ្យបង្កើតក្រុមប្រឹក្សាញាតិមកគ្រប់គ្រង ឬ ចាត់ចែងទ្រព្យសម្បត្តិ និង កូនរបស់អ្នកស្រីឡើយ ។ តុលាការកំពូលគប្បីសំរេចតាមសំណូមពរ ។

ខ-/ ទ្រព្យសម្បត្តិ និង កូនដែលតុលាការបានសំរេចជាស្ថាពរ ប្រគល់ឱ្យអ្នកស្រីយស់ សុគន្ធារី រួចហើយមានតែអ្នកស្រី យស់ សុគន្ធារី ទេ ដែលមានសិទ្ធិគ្រប់គ្រងថែរក្សាចាត់ចែងលើទ្រព្យសម្បត្តិ និង កូន ឬក៏អ្នកស្រីមានសិទ្ធិប្រគល់សិទ្ធិឱ្យជនណាគ្រប់គ្រង ថែរក្សាចាត់ចែងជំនួសបាន ។

គ-/ លោកឃឹម សុជាត ត្រូវបានតុលាការសំរេចឱ្យលែងលះគ្នា ជាមួយអ្នកស្រីយស់ សុគន្ធារី រួចជាស្ថាពរទៅហើយ ដូច្នេះតាមគោលការណ៍ច្បាប់ លោកពុំមានគុណសម្បត្តិមកប្តឹងសុំបង្កើតក្រុមប្រឹក្សាញាតិ ដើម្បីគ្រប់គ្រង ថែរក្សា និងចាត់ចែងទ្រព្យសម្បត្តិ និងកូនរបស់អ្នកស្រីយស់ សុគន្ធារី បានឡើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧០"ឈ" ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី**

១- ទទួលបណ្ដឹងសាទុក្ខលើកទី២លេខ២៣៧ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១របស់លោកឃឹម សុផាត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៧០"ឈ" ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្ដី ចំនួន១៩.០០០រៀល ដែលលោកឃឹម សុផាត បានបង់ទុកជាមុនគឺ :

- ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៥- សាលដីកានេះជំនុំជំរះ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ និងប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៤ ។